ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លេខ...០៣៩...ន.សផក

ថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៥

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ការិយាល័យ... ចូល លេខ 1109 ថ្ងៃ 28 02 25 ម៉ោង... ហត្ថលេខា...

...ខុទ្ទកាល័យ ចូល លេខ 1129 ថ្ងៃ 4.3.25 ហត្ថលេខា...

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ:** អំពីរបាយការណ៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

**យោង:**
- សេចក្តីជូនដំណឹងលេខ១៤១ ដនស/សផក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ស្តីពីការអនុវត្តផែនការសវនកម្ម និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៥ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ៥១ អរប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ៥២ អរប ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា របាយការណ៍សវនកម្មផ្ទៃក្នុងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ជារបាយការណ៍អនុវត្តតាមគំរូស្តង់ដារបាយការណ៍សវនកម្ម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឱ្យគ្រប់ក្រសួង-ស្ថាប័នអនុវត្តតាម ហើយរបាយការណ៍នេះក៏នឹងត្រូវផ្ញើជូន អាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

ឆ្លងតាមការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា ការគ្រប់គ្រង និងប្រើប្រាស់ថវិកា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ មានចំណុចល្អមួយចំនួនដូចជា៖

- កិច្ចបញ្ជិកា ការរៀបចំរក្សាឯកសារគណនេយ្យ ឯកសាររណប និងការកត់ត្រាមានសណ្តាប់ធ្នាប់ល្អជាងឆ្នាំកន្លងមក។
- ការអនុវត្តតាមអនុសាសន៍ដែលប្រតិភូសវនកម្មផ្ទៃក្នុងបានផ្តល់ជូនសម្រាប់ការិយបរិច្ឆេទកន្លងមកបានល្អប្រសើរ។

**ទន្ទឹមនឹងនោះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា÷**

**១-រចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរ**

-មន្ទីរមានថ្នាក់ដឹកនាំដែលជាអនុប្រធានមន្ទីរចំនួនតែ ០២រូប ប៉ុណ្ណោះ មិនទាន់ឆ្លើយតបទៅនឹងទំហំការងារបច្ចុប្បន្នរបស់មន្ទីរនៅឡើយ។

**២-ការងារប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)**

-បន្ទប់ដាក់ម៉ាស៊ីនមេ (Server) បន្ទប់ការិយាល័យ**GIS** និងឃ្លាំងទុកដាក់រក្សាឯកសារ ពុំទាន់មានបំពាក់ប្រព័ន្ធការពារអគ្គីភ័យ។

**៣-ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី**

-តាមបណ្តាស្រុកដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច ក្រុមការងារចុះបញ្ជីដីធ្លីមិនបានបញ្ជូនសំណុំឯកសារពាក់ព័ន្ធមកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក។

-ក្រុមការងារចុះបញ្ជីដីធ្លី មិនបាន Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរ។

-មន្ទីរមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលខូចចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្នចំនួន **១៩,៣១៤** សន្លឹក។

-តាមការពិនិត្យ និងសាកសួរមន្ត្រីជំនាញឃើញថា បណ្តាការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក យឺតយ៉ាវក្នុងការធ្វើបច្ចុប្បន្នភាពចុះសម្រង់បញ្ជីបន្ត ក្នុងសៀវភៅគោលបញ្ជីដីធ្លី។

**៤-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

-តាមការពិនិត្យតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២៣ ឃើញថា មន្ទីរមានទោចក្រយានយន្តចំនួន ០៥ គ្រឿងដែលបានបាត់បង់ ប៉ុន្តែមិនទាន់បានស្នើសុំទៅគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីវាយតម្លៃ រួចហើយធ្វើការជម្រះបញ្ជីចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរនៅឡើយ។

**៥-ការអនុវត្តការងារសំណង់**

១.តាមការពិនិត្យរបាយការណ៍លទ្ធផលការងារឆ្នាំ២០២៤ ឃើញថា÷

-ពុំមានទិន្នន័យ លិខិតបើកការដ្ឋាន និងវិញ្ញាបនបត្រប្រើប្រាស់សំណង់។

-ពុំមានទិន្នន័យ លិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់។

២.ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក មិនបានបញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់ មកការិយាល័យសំណង់របស់មន្ទីរ។

**ប្រតិភូសវនកម្មបានផ្តល់អនុសាសន៍កែលម្អដូចខាងក្រោម÷**

១-មន្ទីរគួរពិចារណាស្នើសុំតែងតាំងអនុប្រធានមន្ទីរ ០១ រូប បន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងទំហំការងារមមាញឹកជាក់ស្តែង។

២-មន្ទីរត្រូវបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ(Server) បន្ទប់ការិយាល័យ**GIS** និងឃ្លាំងទុកដាក់រក្សាឯកសារជាបន្ទាន់។

៣-មន្ទីរត្រូវ÷

-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីបណ្តាក្រុង-ស្រុកដែលបានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរួច បញ្ជូននូវរាល់សំណុំឯកសារពាក់ព័ន្ធ មកការិយាល័យសុរិយោដីរបស់មន្ទីរ និងទៅកាន់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ឱ្យបានទៀងទាត់។

-ជំរុញក្រុមការងារចុះបញ្ជីដីធ្លីធ្វើការ Scan រក្សាទុក នូវទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចុះបញ្ជីរួចរាល់ជាស្ថាពរឱ្យបានពេញលេញ។

-ធ្វើបច្ចុប្បន្នភាពសន្លឹកបណ្ណខូច រួចហើយស្នើសុំបង្កើតគណៈកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងប្លូកសរុប ដើម្បីដុតកម្ទេច ស្របតាមលិខិតលេខ៣២៩ អ/សដក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

-ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ធ្វើការចុះបញ្ជីបន្តនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ឱ្យបានពេញលេញ។

៤-មន្ទីរត្រូវរួសរាន់ក្នុងការកែតម្រូវសៀវភៅកើនឡើងឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំ២០២៤ ដើម្បីជៀសវាងមានការចុះច្រឡំបន្តថា មានការបាត់បង់ទោចក្រយានយន្តចំនួន ០៥គ្រឿង នៅក្នុងសៀវភៅកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរ ប្រចាំឆ្នាំ២០២៤។

៤-ចំពោះការងារសំណង់ មន្ទីរត្រូវ÷

-រំលេចទិន្នន័យ លិខិតបើកការដ្ឋាន វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ នៅក្នុងរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំរបស់មន្ទីរ ព្រមទាំងខិតខំជំរុញការផ្សព្វផ្សាយណែនាំឱ្យម្ចាស់សំណង់មកស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់ និងស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ក្រោយបញ្ចប់ការសាង

សង់។ មន្ទីរក៏ត្រូវណែនាំក្រុមជាងសំណង់ឱ្យមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់មុនពេលដំណើរការអាជីវកម្ម ស្របតាមសារាចរណែនាំស្តីពីការគ្រប់គ្រងក្រុមជាងសំណង់លេខ០០១ ជនស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។

- ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់មកការិយាល័យសំណង់របស់មន្ទីរ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

**យួន_សុជាតិ**

| **មតិឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** | **មតិឯកឧត្តមប្រធានក្រុមការងារ** |
|---|---|
| | |

**មតិសម្រេចឯកឧត្តមឧបនាយករដ្ឋមន្ត្រី**